**៣៩ ស.** *នៅពេល គ.ស.ប មានតំណាងនៅតាមឃុំ/សង្កាត់មួយចំនួនហើយ តើពួកគាត់ អាចជួយ គ.ស.ប ដោយរបៀបណា ដើម្បីឈានទៅសម្រេចគោលដៅរបស់ខ្លួន?*

**ឆ.** ការមានសមាជិក គ.ស.ប មួយចំនួនក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់គឺជាការបញ្ជាក់ប្រាប់ទៅដល់ពលរដ្ឋខ្មែរគ្រប់រូប ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល បណ្តាញផ្សព្វផ្សាយព័ត៌មាន និងអង្គទូតនានាដែលកន្លងមកបានធ្វើមិនដឹង មិនឮចំពោះ គ.ស.ប ថា គ.ស.ប ពិតជាមានអត្ថិភាព នៅក្នុងប្រទេសកម្ពុជា ហើយកំពុងតែធ្វើនយោបាយយ៉ាងសកម្ម ដោយមានគោលដៅ គោលបំណង និងផែនការសកម្មភាពច្បាស់លាស់ ដោយឈរលើមូលដ្ឋានសុចរិត។

សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់របស់ គ.ស.ប នឹងអាចចូលរួមពង្រឹងមូលដ្ឋានតាមរយៈ ការផ្សព្វផ្សាយចំណេះដឹង និងទស្សនៈនៃការធ្វើនយោបាយរបស់ខ្លួនឱ្យបានកាន់តែទូលំទូលាយតាមរយៈការជួបប្រជុំ ការរៀបចំធ្វើវេទិកា និងការផ្សព្វផ្សាយតាមរូបភាពផ្សេងៗទៀត ទៅតាមស្ថានភាពនៅតាមឃុំ/សង្កាត់នីមួយៗ ដើម្បីកៀងគរការចូលរួមរបស់ប្រជាពលរដ្ឋពីគ្រប់និន្នាការនយោបាយឱ្យចូលរួមកសាងប្រទេសកម្ពុជាឲ្យទៅជាសង្គមមួយដែលពលរដ្ឋគ្រប់រូបរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់។

ទីណាមានសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់របស់ គ.ស.ប ដែលជាភ្នាក់ងារពង្រីកអំពើល្អ ទីនោះនឹងមានអំពើយុត្តិធម៌សង្គមកាន់តែរីកដុះដាលឡើង។

**៣៨ ស.** *នៅពេល គ.ស.ប មានតំណាងនៅតាមឃុំ/សង្កាត់មួយចំនួនហើយ តើពួកគាត់អាចជួយឃុំ/សង្កាត់ដោយរបៀបណា?*

**ឆ.** សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់របស់ គ.ស.ប នឹងបំពេញតួនាទីរបស់ខ្លួនទៅតាមច្បាប់ ប៉ុន្តែឈរលើមូលដ្ឋាននៃការធ្វើនយោបាយរបស់ គ.ស.ប។ តួនាទីរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់របស់ គ.ស.ប ក្នុងការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធឃុំ/សង្កាត់ ពិតជាមានកម្រិត ប៉ុន្តែសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់របស់ គ.ស.ប នឹងត្រូវធ្វើជាគំរូនៅក្នុងឃុំ/សង្កាត់ តាមរយៈការបំពេញការងារដោយស្អាតស្អំ និងចាត់ទុកប្រជាពលរដ្ឋក្នុងសហគមន៍គឺជាម្ចាស់ខ្លួនយ៉ាងពិតប្រាកដ ដើម្បីជំរុញ ឱ្យមានអភិបាលកិច្ចល្អនៅតាមមូលដ្ឋាន។

**៣៧ ស.** *ហេតុអ្វីបានជាខ្ញុំឈរឈ្មោះបោះឆ្នោតធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ឱ្យ គ.ស.ប?*

**ឆ.** ពីព្រោះ គ.ស.ប គឺជាគណបក្សដែល ៖

- កំណត់គោលដៅច្បាស់លាស់ដែលប្រជាពលរដ្ឋគ្រប់រូបអាចយល់ដឹងបាន(គោលដៅទៅកាត់បន្ថយអំណាចរដ្ឋតាមរយៈយន្តការប្រាំបីចំណុច)
- យកចិត្តទុកដាក់លើដំណោះស្រាយជាងលើបញ្ហា
- ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយឥតលាក់លៀម
- លើកតម្កើងវប្បធម៌នៃការចូលរួមដោយការយល់ដឹងរបស់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់និន្នាការនយោបាយ
- ចាត់ទុករឿងនយោបាយជារឿងរបស់ប្រជាពលរដ្ឋគ្រប់រូប
- ចាត់ទុកប្រជាពលរដ្ឋ និងប្រព័ន្ធនយោបាយជាចលករដើម្បីដោះស្រាយបញ្ហាសង្គម
- ប្រើប្រាស់បេះដូងសុចរិតទៀងត្រង់ និងទស្សនវិស័យភ្លឺថ្លាដើម្បីកៀងគរការចូលរួម
- បង្កើតចលនារួបរួមគ្នានៅលើមនោគមវិជ្ជានយោបាយដើម្បីសង្គ្រោះជាតិ
- ចាត់ទុកតួនាទីក្នុងនយោបាយជាការលះបង់ទាំងកម្លាំងកាយ ចំណេះដឹង និងថវិកា
- ពន្យល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងដើម្បីបោះឆ្នោតគាំទ្រប្រព័ន្ធ (យន្តការប្រាំបីចំណុច)
- យកមេរៀនព្រះពុទ្ធមកបដិបត្តិទាំងសម្រាប់ការរស់នៅ និងសម្រាប់ការធ្វើនយោបាយ
- ចែករំលែកប្រយោជន៍ និងសេចក្តីសុខផ្ទាល់ខ្លួនដើម្បីប្រយោជន៍ និងសេចក្តីសុខអ្នកដទៃ
- ឈឺឆ្អាល និងជួយដោះស្រាយបញ្ហាអ្នកដទៃ ដោយគ្មានចង់បានអ្វីតបវិញគឺចង់ត្រឹមតែជួយ
- នាំឱ្យស្ពឹងលោកធម៌ទាំង៨គឺលាភ (អលាភ) យស (អយស) សរសើរ (និន្ទា) និងសុខ (ទុក្ខ)
- រួមចំណែកដល់ការទាញយកអំណាចមកគ្រប់គ្រងដោយប្រជាពលរដ្ឋ
- លុបបំបាត់ការមើលបំណាំគ្នា ការគុំគួនគ្នា ទំនាស់គ្នាដោយសារអ្នកនយោបាយ ឬគណបក្សនយោបាយ
- លុបបំបាត់នយោបាយបោកបញ្ឆោតគ្នា ដែលប្រើប្រាស់សំដីគ្មានការពិត
- បង្កើតអ្នកដឹកនាំឱ្យបានច្រើន ជាជាងបង្កើតអ្នកដើរតាមពិសេសគឺសកម្មជននយោបាយដែលកំពុងធ្វើព្យុះភ្លៀងតាមចិត្តនៅតាមមូលដ្ឋាន

បង្កើតបណ្តាញក្នុងការផ្សព្វផ្សាយទស្សនវិស័យថ្មីៗរបស់ គ.ស.ប ទៅដល់គ្រប់ប្រជាពលរដ្ឋខ្មែរ

**៣៦ ស.** *តើព្រះធម៌មានទំនាក់ទំនងយ៉ាងណាជាមួយនឹងទង្វើរបស់ គ.ស.ប?*

**ឆ.** ព្រះធម៌ជាមេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធ។ គ.ស.ប ដកស្រង់មេរៀនមួយចំនួនតែប៉ុណ្ណោះដែលខ្លួនយល់ឃើញថាមានទំនាក់ទំនងទៅនឹងគោលធំៗទាំងបីរបស់ គ.ស.ប គឺប្រជាធិបតេយ្យ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គម ដើម្បីឱ្យប្រជាពលរដ្ឋស្គាល់តម្លៃពិតប្រាកដរបស់ជីវិត កសាងដួងចិត្តបរិសុទ្ធ ដើម្បីដោះស្រាយបញ្ហារបស់ ប្រជាពលរដ្ឋតាមរយៈតួនាទីនយោបាយ និងសាសនា និងកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋដែលគាំទ្រចលនារបស់ គ.ស.ប។ មេរៀនទាំងនោះទាក់ទងទៅនឹងជីវិត និងការរស់នៅ ដើម្បីបានជាប្រយោជន៍អ្នកដទៃផង ប្រយោជន៍ខ្លួនឯងផង ដោយយកព្រះធម៌ជាមូលដ្ឋានគ្រឹះ ផ្សាភ្ជាប់នឹងឧទាហរណ៍ជាក់ស្តែងនៃការរស់នៅ និងការបដិបត្តិព្រះធម៌របស់ប្រជាពលរដ្ឋ។ មេរៀនទាំងនេះមានចាក់ផ្សាយរៀងរាល់ថ្ងៃនៅវិទ្យុសំបុកឃ្មុំ FM105 ចាប់ពីម៉ោង ២-៣ រសៀលនៅភ្នំពេញ និងវិទ្យុ នៅខេត្តដទៃទៀត និងមាននៅក្នុងគេហទំព័រ www.camldp.org។

**៣៥ ស.** *ហេតុអ្វីបានជា គ.ស.ប យកព្រះធម៌មកលាយឡំនឹងការធ្វើនយោបាយ?*

**ច.** ប្រជាពលរដ្ឋកំពុងតែរស់នៅដោយរងការបំផ្លាញពីអ្នកនយោបាយ ដែលចាត់ទុកនយោបាយគឺជាមុខរបរ និងពីសំណាក់ព្រះសង្ឃ និងធម្មាចារ្យមួយចំនួនដែលកំពុងតែបានលាតសក្ការៈពីការយកសាសនាមកធ្វើជាឈ្នាន់ ដើម្បីកេងចំណេញពីប្រជាពលរដ្ឋដែលគ្រាន់តែប្រើប្រាស់មេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធត្រឹមតែជាជំនឿ និងការចាំមាត់តែប៉ុណ្ណោះ។ គ.ស.ប ពន្យល់ពលរដ្ឋឱ្យយល់អំពីបញ្ហាទាំងនេះ ដើម្បីឱ្យពលរដ្ឋរួចផុតពីការបោកប្រាស់ ឱ្យយល់អំពីជីវិត និងយល់អំពីបុណ្យបាប ដើម្បីឱ្យពលរដ្ឋក្លាយជាពលសកម្មក្នុងការចូលរួមសកម្មភាពសង្គម។ ក្នុងន័យនេះ គ.ស.ប យល់យ៉ាងច្បាស់ថា គ្មានការធ្វើបុណ្យណាបានបុណ្យច្រើនជាងការធ្វើនយោបាយ ដើម្បីជួយពលរដ្ឋចំនួនច្រើនឱ្យរួចផុតពីបញ្ហាច្រើនប្រភេទ ដោយបេះដូងជួយសង្គ្រោះ និងមានទស្សនវិស័យច្បាស់លាស់នោះទេ។ម្យ៉ាងវិញទៀត នយោបាយជាអាយុជីវិតរបស់ប្រជាពលរដ្ឋគ្រប់រូប រីឯព្រះធម៌ជាមេរៀនជីវិតរបស់មនុស្សគ្រប់រូបដែរ។ ដូច្នេះ ការយកព្រះធម៌មកប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃជារឿងត្រឹមត្រូវណាស់។

**៣៤ ស.** *អ្វីជាគុណវិបត្តិនៃប្រព័ន្ធបោះឆ្នោតបច្ចុប្បន្ននៅកម្ពុជា?*

**ច.** ការបោះឆ្នោតតាមប្រព័ន្ធសមាមាត្រដូចបច្ចុប្បន្ននេះ មិនមែនជាការបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋនោះទេ វាជាប្រព័ន្ធបោះឆ្នោតជ្រើសរើសបក្ស។ មេបក្សជាអ្នកសម្រេចក្នុងការជ្រើសរើសតំណាងរាស្ត្រ ដូច្នេះតំណាងរាស្ត្រទាំងនោះបំពេញការងារឱ្យបក្សច្រើនជាងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ។ ប្រព័ន្ធបោះឆ្នោតបែបនេះគ្រាន់តែផ្តល់សិទ្ធិឱ្យប្រជាពលរដ្ឋតែប៉ុណ្ណោះ ប៉ុន្តែពួកគាត់មិនមានអំណាចដើម្បីប្រើប្រាស់សិទ្ធិនោះទេ ពីព្រោះប្រជាពលរដ្ឋមិនបានបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដោយផ្ទាល់ ហើយប្រជាពលរដ្ឋក៏មិនមែនជាអ្នកដកតំណាងរាស្ត្រនោះដែរ។ មេបក្សជាអ្នកជ្រើសរើស និងជាអ្នកដកតំណាងរាស្ត្រ។ ដូច្នេះ អំណាចទាំងអស់ត្រូវធ្លាក់ទៅលើមេបក្សតែម្នាក់ប៉ុណ្ណោះ។

**៣៣ ស.** *អ្វីទៅជាកាតព្វកិច្ចក្នុងភាពជាម្ចាស់?*

**ច.** ក្នុងភាពជាម្ចាស់ប្រជាពលរដ្ឋមានសិទ្ធិ និងកាតព្វកិច្ចក្នុងការជ្រើសរើសតំណាងរបស់ខ្លួន នៅគ្រប់កម្រិតទាំងអស់ និងគ្រប់ពេលលើកលែងតែតំណាងណាដែលត្រូវផ្លាស់ប្តូរនៅពេលចប់អាណត្តិ ឬកំណត់ដោយច្បាប់ តាមរយៈការបោះឆ្នោតដោយចំមុខ ដើម្បីជ្រើសរើសតំណាងទៅទទួលខុសត្រូវក្នុងការចាត់ចែងការងារស្រុកទេស និងបោះឆ្នោតដកចេញវិញនៅពេលតំណាងនោះមិនបំពេញការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីឆ្លើយតបផលប្រយោជន៍ពលរដ្ឋដែលជាម្ចាស់ប្រទេស។

**៣២ ស.** *តើពលរដ្ឋជាម្ចាស់ប្រទេសមានន័យយ៉ាងដូចម្តេច?*

**ច.** នៅក្នុងគ្រួសាររបស់អ្នក អ្នកគឺជាម្ចាស់ ដូច្នេះអ្នកមានសិទ្ធិចាត់ចែងគ្រប់យ៉ាងដើម្បីផលប្រយោជន៍គ្រួសារអ្នក។ អ្នកមានសិទ្ធិសម្រេចអំពីជោគវាសនាគ្រួសារអ្នក។ ប្រជាពលរដ្ឋគឺជាម្ចាស់ប្រទេសតាមរយៈតំណាង។ ដោយសារពលរដ្ឋមានចំនួនច្រើន តំណាងនៅគ្រប់លំដាប់ (ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី និងជាតិ) ដែលប្រជាពលរដ្ឋជាអ្នកជ្រើសរើសដោយផ្ទាល់តាមរយៈការបោះឆ្នោត នឹងបំពេញកាតព្វកិច្ចគ្រប់យ៉ាងដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសពិតប្រាកដ។

**៣១ ស.** *នៅពេលកម្ពុជាក្លាយជាសង្គមប្រជាធិបតេយ្យ តើពលរដ្ឋត្រូវធ្វើអ្វីខ្លះ?*

**ច.** ការចូលរួមរបស់ពលរដ្ឋដើម្បីតាមដានដំណើរការរបស់សង្គម នៅតែជាការចាំបាច់។ ប្រជាពលរដ្ឋត្រូវតាមដានសកម្មភាពតំណាងរបស់ខ្លួន ក្នុងការបំពេញកាតព្វកិច្ចទៅតាមការសន្យា ឬបោះឆ្នោតទម្លាក់តំណាងនោះវិញ ប្រសិនបើមិនបានបំពេញការងារត្រឹមត្រូវ ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ។ ការតាមដានបែបនេះអាចមានប្រសិទ្ធភាពលុះណាតែប្រជាពលរដ្ឋខិតខំតាមដានព្រឹត្តិការណ៍សង្គមតាមរយៈការអាន ការស្តាប់ឱ្យបានជាប់ជាប្រចាំ ដូចជាការហូបបាយប្រចាំថ្ងៃយ៉ាងដូច្នេះដែរ។

**៣០ ស.** *តើ គ.ស.ប ចាប់ផ្តើមកសាងសង្គមមួយដែលប្រជាពលរដ្ឋគ្រប់រូបរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់ដោយរបៀបណា?*

**ច.** សង្គមមួយដែលប្រជាពលរដ្ឋគ្រប់រូបរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់មិនអាចកើតឡើងបានទេ ប្រសិនបើគ្មានការរួមគិត រួមធ្វើ និងរួមទទួលខុសត្រូវពីប្រជាពលរដ្ឋ។ ដូច្នេះ គ.ស.ប កៀងគរប្រជាពលរដ្ឋឱ្យចូលរួមតាមរយៈការពន្យល់លើគោលជំហរបី គឺប្រជាធិបតេយ្យ/នយោបាយ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គម ដើម្បីឲ្យប្រជាពលរដ្ឋមានមូលដ្ឋានពិចារណាអំពីជីវិត តម្លៃជីវិត បុព្វហេតុជីវិត នោះទើបពលរដ្ឋសកម្ម ថ្លៃថ្នូរ និងមានការទទួលខុសត្រូវទាំងនោះមកចូលរួមបង្កើតសង្គមប្រជាធិបតេយ្យមួយ ដែលប្រជាពលរដ្ឋគ្រប់រូបអាចរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់បាន។

**២៩ ស.** *តើប្រជាពលរដ្ឋអាចចូលរួមជាមួយ គ.ស.ប ដោយរបៀបណា?*

**ច.** ដើម្បីចូលរួមជាមួយ គ.ស.ប ពលរដ្ឋត្រូវតែយល់ច្បាស់អំពី គ.ស.ប និងយល់កាន់តែច្បាស់ទៅទៀតអំពីខ្លួនឯងមុននឹងប្រជាពលរដ្ឋសម្រេចចូលរួមជាមួយ គ.ស.ប តាមរយៈការលះបង់ភាពអាត្មានិយម ដើម្បីប្រយោជន៍ និងសេចក្តីសុខរួម ដូចជាការចូលរួមកម្លាំងកាយ ការចូលរួមថវិកា និងការចូលរួមចំណេះដឹង។

**២៨ ស.** *តើត្រូវមានការរៀបចំយ៉ាងដូចម្តេចដើម្បីធ្វើឱ្យអំណាចទាំងបីនេះដាច់ចេញពីគ្នា?*

**ច.** ប្រើប្រាស់ការបោះឆ្នោតដោយប្រជាពលរដ្ឋ ដោយចំមុខ ដើម្បីជ្រើសរើសតំណាងឱ្យបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាន ដូចជាការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ បោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា ចៅហ្វាយខេត្ត ចៅហ្វាយស្រុក មេឃុំ និងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដោយតំណាងរាស្ត្រ ដើម្បីជ្រើសតាំងនាយករដ្ឋមន្ត្រី។

**២៧ ស.** *អំណាចរដ្ឋមានអ្វីខ្លះ?*

**ច.** អំណាចរដ្ឋមានបីគឺអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ នៅក្នុងសង្គមប្រជាធិបតេយ្យអំណាចទាំងបីនេះត្រូវបានកាត់ផ្តាច់ចេញពីគ្នា ដើម្បីធានាតុល្យភាពនៃដំណើរការរដ្ឋ។

**២៦ ស.** *ការបោះឆ្នោតដោយប្រព័ន្ធសមាមាត្រ និងការបោះឆ្នោតដោយប្រព័ន្ធចម្រុះមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច ហើយមានទំនាក់ទំនងយ៉ាងណាទៅនឹងអំណាចរដ្ឋ និងអំណាចប្រជាពលរដ្ឋ?*

**ច.** ប្រព័ន្ធបោះឆ្នោតនៅកម្ពុជានាពេលបច្ចុប្បន្នគឺជាប្រព័ន្ធបោះឆ្នោតជ្រើសរើសបក្ស។ ដូច្នេះ តំណាងរាស្ត្រ ចៅហ្វាយខេត្ត ចៅហ្វាយស្រុក មេឃុំ និងមេភូមិត្រូវបានជ្រើសរើស និងទម្លាក់ដោយមេបក្សដែលកាន់អំណាច។ ពួកគាត់នឹងចាត់ទុកប្រធានរបស់គាត់ ថ្នាក់លើគាត់ជាបន្តបន្ទាប់រហូតដល់នាយករដ្ឋមន្ត្រីថាជាម្ចាស់របស់គាត់ ហើយចាត់ទុកប្រជាពលរដ្ឋជាកូនជាចៅគ្មានអំណាចអ្វីនោះទេ។ អំណាចទាំងអស់គឺជាអំណាចរបស់មេបក្ស។ នេះជាផលវិបាកនៃការបោះឆ្នោតដោយប្រព័ន្ធសមាមាត្រ។ នៅពេលមេឃុំត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋ និងទម្លាក់ដោយប្រជាពលរដ្ឋ ដោយចំមុខ ពួកគាត់នឹងចាត់ទុកប្រជាពលរដ្ឋគឺជាម្ចាស់របស់គាត់ ហើយប្រធានរបស់គាត់នៅថ្នាក់លើគាត់ជាបន្តបន្ទាប់រហូតដល់នាយករដ្ឋមន្ត្រី ថាជាអ្នកទទួលខុសត្រូវការងារដឹកនាំស្រុកទេសដែលមានប្រជាពលរដ្ឋគឺជាម្ចាស់អំណាចពិតប្រាកដ។ នេះគឺជាលទ្ធផលនៃការបោះឆ្នោតដោយប្រព័ន្ធចម្រុះ។

**២៥ ស.** *ការបំបែកអំណាចរដ្ឋមានអត្ថន័យយ៉ាងដូចម្តេច?*

**ច.** ការបំបែកអំណាចរដ្ឋមានអត្ថន័យថា៖

- ផ្តល់សិទ្ធិ អំណាច និងការទទួលខុសត្រូវទៅឱ្យស្ថាប័នដែលនៅជិតប្រជាពលរដ្ឋ។
- អំណាចនៃការសម្រេចអំពីវាសនាប្រទេសជាតិស្ថិតនៅក្នុងដៃរបស់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ពេលតាមរយៈតំណាងនៅថ្នាក់ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី និងជាតិ។
- រាល់ការសម្រេចទាំងកិច្ចការដឹកនាំរដ្ឋ និងកិច្ចការអភិវឌ្ឍជាតិលើគ្រប់វិស័យត្រូវធ្វើឡើងតាមសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេស។

**២៤ ស.** *មានអ្វីអាចបំបែកអំណាចរដ្ឋបាន?*

**ច.** លុះត្រាតែមានប្រព័ន្ធមួយទៅបំបែកអំណាចរដ្ឋ ហើយប្រព័ន្ធនោះអាចរុញច្រានឲ្យមានការពង្រឹងអំណាចប្រជាពលរដ្ឋឲ្យមានតុល្យភាពអំណាចរវាងអំណាចរដ្ឋ និងអំណាចប្រជាពលរដ្ឋ នោះទើបបំបែកអំណាចរដ្ឋបាន។

**២៣ ស.** *រដ្ឋដែលប្រមូលផ្តុំអំណាចមានលក្ខណៈដូចម្តេច?*

**ច.** រដ្ឋដែលប្រមូលផ្តុំអំណាចគឺជារដ្ឋដែល ៖

- បុគ្គលម្នាក់ ឬមួយក្រុមជាអ្នកសម្រេចកិច្ចការគ្រប់ជាន់ថ្នាក់របស់ប្រទេសជាតិ។
- រាល់ការសម្រេចត្រូវធ្វើទៅតាមការចង់បានរបស់ថ្នាក់លើ និងបម្រើផលប្រយោជន៍ថ្នាក់លើ។
- មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិរុញការទទួលខុសត្រូវ ទៅឱ្យមន្ត្រីនៅថ្នាក់លើជាបន្តបន្ទាប់ ពោលគឺ ឃុំរុញទៅស្រុក ស្រុករុញទៅខេត្ត និងខេត្តរុញទៅថ្នាក់ជាតិដើម្បីបង្ហាញប្រជាពលរដ្ឋថា ខ្លួនមិនមែនជាអ្នកមានកំហុសនោះទេ។
- អនុវត្តទម្រង់នៃការដឹកនាំដែលងាយនឹងឈានទៅរករបបផ្តាច់ការ និងមានគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុត ចំពោះការបំផ្លាញជាតិ និងការបាត់បង់ទឹកដី។

**២២ ស.** *អ្នកណាជាអ្នកបង្កើតសង្គមប្រជាធិបតេយ្យ?*

**ច.** សង្គមប្រជាធិបតេយ្យគឺជាសង្គមរបស់ប្រជាពលរដ្ឋ បង្កើតឡើងដោយប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ។ ដូច្នេះ ប្រជាពលរដ្ឋគ្រប់រូបត្រូវតែចូលរួមដើម្បីបង្កើតសង្គមប្រជាធិបតេយ្យ។

**២១ ស.** *អ្វីទៅជាសង្គមប្រជាធិបតេយ្យ?*

**ច.** សង្គមប្រជាធិបតេយ្យគឺជាសង្គមមួយដែលការដឹកនាំស្រុកទេសត្រូវសម្រេច និងទទួលខុសត្រូវដោយប្រជាពលរដ្ឋ ដែលជាម្ចាស់តាមរយៈតំណាងដែលត្រូវបានបោះឆ្នោតដោយចំមុខ ដោយសេរី ដោយទៀងទាត់ និងដោយស្មើភាពគ្នា - ពោលគឺការបោះឆ្នោតជ្រើសរើសតំណាង ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី និងតំណាងរាស្ត្រ និងការបោះឆ្នោតដើម្បីដកតំណាងទាំងនោះចេញពីតំណែងវិញ នៅពេលដែលតំណាងទាំងនោះមិនបានបំពេញការងារឆ្លើយតបផលប្រយោជន៍ជូនប្រជាពលរដ្ឋ។

**២០ ស.** *តើអ្វីទៅជាផលដែលកើតចេញពីប្រជាធិបតេយ្យ?*

**ច.**

១. តុល្យភាពអំណាចរវាងអ្នកកាន់ការងារស្រុកទេស និងប្រជាពលរដ្ឋជាម្ចាស់ប្រទេស (តាមរយៈតំណាង) ត្រូវបានធានា។

២. ស្ថិរភាពនយោបាយ និងជោគវាសនាប្រទេសជាតិស្ថិតក្នុងកណ្តាប់ដៃប្រជាពលរដ្ឋត្រូវបានធានា។

៣. ការប្រឈមមុខគ្នាដោយអាវុធ ត្រូវបានបញ្ចៀស និងរាល់បញ្ហា ឬវិបត្តិនយោបាយត្រូវបានដោះស្រាយតាមរយៈការពិភាក្សាដោយឈរលើមូលដ្ឋានច្បាប់។

៤. យុត្តិធម៌សង្គមត្រូវបានធានា និងការគោរពសិទ្ធិមនុស្សត្រូវបានលើកកម្ពស់ រួមទាំងការអនុវត្តគោលការណ៍នីតិរដ្ឋ។

៥. ប្រជាពលរដ្ឋមានឱកាសស្មើគ្នាក្នុងការចូលរួម និងទទួលបានផលពីការអភិវឌ្ឍសង្គម។

៦. អ្នកនយោបាយ និងមន្ត្រីរាជការការពារ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋដែលជាម្ចាស់អំណាច។

**១៩ ស.** *ជាតុផ្សំដើម្បីឱ្យដំណើរការប្រជាធិបតេយ្យប្រព្រឹត្តទៅបានល្អ ៖*

**ច.** ជាតុផ្សំដើម្បីឱ្យដំណើរការប្រជាធិបតេយ្យប្រព្រឹត្តទៅបានល្អមាន៖

- នីតិរដ្ឋ
- ការគោរពសិទ្ធិមនុស្ស
- ការតម្រូវឱ្យមានប្រព័ន្ធផ្សព្វផ្សាយ
- កម្រិតចំណេះដឹងរបស់អ្នកចូលរួម
- កម្រិតសីលធម៌របស់អ្នកចូលរួម

**១៨ ស.** *តើអ្វីខ្លះជាដំណើរការប្រជាធិបតេយ្យ?*

**ច.** ដំណើរការប្រជាធិបតេយ្យជាដំណើរការនៃការចូលរួមក្នុងគ្រប់កិច្ចការប្រទេសជាតិនៃពលរដ្ឋដែលជាម្ចាស់សិទ្ធិ និងម្ចាស់អំណាច។ ប្រជាពលរដ្ឋទាំងនោះត្រូវតែមានការយល់ដឹងច្បាស់លាស់ពីសិទ្ធិ និងអំណាចជាម្ចាស់ និងកាតព្វកិច្ចក្នុងនាមជាម្ចាស់។ ដំណើរការទាំងនេះរួមមាន ៖

- ដំណើរការចូលរួមបោះឆ្នោតជ្រើសរើស និងដកតំណាងគ្រប់ប្រភេទ
- ចូលរួមតាមដានកិច្ចការដែលទាក់ទងនឹងប្រទេសជាតិ
- ចូលរួមជាមួយគណបក្សនយោបាយ អង្គការសង្គមនានា (សមាគម, សហជីព, សហគមន៍, អង្គការសង្គមស៊ីវិល ។ល។)
- ចូលរួមសម្តែងឆន្ទៈតាមរយៈបាតុកម្ម ឬកូដកម្ម រួមទាំងការចូលរួមសម្តែងឆន្ទៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា

រាល់ការអនុវត្តដំណើរការប្រជាធិបតេយ្យត្រូវគោរពគោលការណ៍ដែលប្រជាពលរដ្ឋជាម្ចាស់អំណាច។ ក្នុងករណីភាពជាម្ចាស់អំណាចរបស់ប្រជាពលរដ្ឋ ត្រូវបានរំលោភ (បាត់ភាពជាម្ចាស់) ការអនុវត្តនោះពុំដើរតាមមាគ៌ាប្រជាធិបតេយ្យឡើយ។
ឧទាហរណ៍ ៖ គេថាពលរដ្ឋទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលជាតុពិតពលរដ្ឋទៅបោះឆ្នោតរើសបក្សសោះ។

ដំណើរការប្រជាធិបតេយ្យនេះអាចប្រព្រឹត្តទៅបានមិនអាចខ្វះនូវគោលការណ៍មួយ គឺគោលការណ៍តុល្យភាពរវាងអំណាចរដ្ឋ និងអំណាចប្រជាពលរដ្ឋឡើយ(Checks-and-Balances)។

**១៧ ស.** *អ្វីទៅជាប្រជាធិបតេយ្យ?*

**ច.** ប្រជាធិបតេយ្យគឺជាទម្រង់នៃការគ្រប់គ្រងរដ្ឋដែលសិទ្ធិ និងអំណាចក្នុងការចាត់ចែងកិច្ចការប្រទេសជាតិស្ថិតនៅក្នុងដៃរបស់ប្រជាពលរដ្ឋ ហើយដាច់ខាតត្រូវមានប្រព័ន្ធធានាដល់ការប្រើសិទ្ធិ និងអំណាចជាម្ចាស់របស់ប្រជាពលរដ្ឋជាអចិន្ត្រៃយ៍ ។

**១៦ ស.** *បន្ទាប់ពីប្រែក្លាយយន្តការប្រាំបីចំណុចទៅជាច្បាប់ហើយ តើនឹងមានអ្វីកើតឡើង?*

**ច.** បន្ទាប់ពីប្រែក្លាយយន្តការប្រាំបីចំណុចទៅជាច្បាប់ហើយ នឹងមានការកើតឡើង៖

- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងធានាឱ្យមានតុល្យភាពអំណាចទាំងបី គឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចគឺជាយន្តការរំដោះតំណាងរាស្ត្រ (សមាជិកសភា) ចេញពីក្រញាំមេបក្ស។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចគឺជាយន្តការដែលរំដោះមន្ត្រីរាជការគ្រប់លំដាប់ចេញពីក្រញាំមេបក្សដែលគ្រប់គ្រងរដ្ឋាភិបាល។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងបង្កលក្ខណៈដល់ប្រជាពលរដ្ឋគ្រប់រូបពីគ្រប់និន្នាការនយោបាយ ឱ្យមានឱកាសចូលរួមបង្កើតសង្គមប្រជាធិបតេយ្យពិតប្រាកដដែលពលរដ្ឋរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងធានាឱ្យមានតុល្យភាពអំណាច រវាងអ្នកកាន់ការងារស្រុកទេស និងប្រជាពលរដ្ឋ។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងបញ្ចប់នូវវប្បធម៌បែងចែកបក្សនយោបាយនៅតាមស្ថាប័នរដ្ឋ និងនៅតាមមូលដ្ឋាន។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងធានាឱ្យប្រជាពលរដ្ឋប្រកបរបរចិញ្ចឹមជីវិតដោយគ្មានការគាបសង្កត់ ដោយគ្មានអំពើពុករលួយ ដោយស្មើភាពគ្នា និងទទួលបានផលទៅតាមកម្លាំងកាយ កម្លាំងប្រាជ្ញា និងទុនវិនិយោគរៀងៗខ្លួន។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងធានាឱ្យមានសណ្តាប់ធ្នាប់សង្គម នៅចំពោះមុខច្បាប់ ទាំងកិច្ចការរដ្ឋ និងកិច្ចការជំនួញធំតូចទាំងអស់។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងក្លាយជាមរតកគ្រប់គ្រងសង្គម ដែលផ្តល់សេចក្តីសុខ និងរីកចម្រើនដល់កូនខ្មែរលើគ្រប់វិស័យ គ្រប់ជំនាន់ទៅថ្ងៃមុខ។
- ច្បាប់កើតចេញពីយន្តការប្រាំបីចំណុចនឹងជាមធ្យោបាយទប់ស្កាត់ មិនឱ្យកម្ពុជាក្លាយជាប្រទេសដែលរងការគំរាមកំហែងពីប្រទេសជិតខាង។

**១៥ ស.** *មានអ្វីកើតឡើងចំពោះយន្តការប្រាំបីចំណុច នៅក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ២០១៣?*

**ច.** នៅពេល គ.ស.ប មានសំឡេងគាំទ្រគ្រប់គ្រាន់ រដ្ឋាភិបាលដែលតំណាង គ.ស.ប នឹងប្រែក្លាយយន្តការប្រាំបីចំណុច ឱ្យក្លាយទៅជាច្បាប់ដើម្បីកាត់បន្ថយអំណាចរដ្ឋ។ ក្នុងករណីដែល គ.ស.ប ទទួលបានសំឡេងមិនគ្រប់គ្រាន់ គ.ស.ប នឹងបន្តផ្សព្វផ្សាយយន្តការនេះបន្តទៅទៀត តាមគ្រប់រូបភាព ទៅដល់ប្រជាពលរដ្ឋទូទាំងប្រទេស តាមលទ្ធភាពដែលខ្លួនអាចធ្វើបាន។

**១៤ ស.** *ដើម្បីដាក់យន្តការប្រាំបីចំណុចនៅក្នុងប្រទេសកម្ពុជា តើ គ.ស.ប ត្រូវចាប់ផ្តើមធ្វើការងារអ្វីមុនគេ?*

**ច.** ដើម្បីឈានទៅដាក់យន្តការ ៨ ចំណុច នៅស្រុកខ្មែរ គ.ស.ប បាន និងកំពុងពន្យល់ប្រជាពលរដ្ឋឱ្យគាំទ្រទស្សនៈថ្មីនៃការធ្វើនយោបាយ។ យើងពន្យល់ប្រជាពលរដ្ឋឲ្យផ្លាស់ប្តូរផ្នត់គំនិតលើគោលធំៗចំនួនបី គឺប្រជាធិបតេយ្យ/នយោបាយ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គម។ លុះត្រាតែប្រជាពលរដ្ឋផ្លាស់ប្តូរផ្នត់គំនិតលើគោលធំៗទាំងបីនេះជាមុនសិន ទើបប្រជាពលរដ្ឋមានការយល់ដឹង សកម្ម និងថ្លៃថ្នូរទាំងនោះមកគាំទ្រការដាក់យន្តការ ៨ ចំណុចនៅស្រុកខ្មែរ។

**១៣ ស.** *ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមប្រព័ន្ធចម្រុះ មានសារៈសំខាន់អ្វីខ្លះ?*

**ច.** ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមប្រព័ន្ធចម្រុះ គឺជាការបោះឆ្នោតឱ្យបក្សផង និងឱ្យបុគ្គលដែលឈរឈ្មោះឱ្យបក្សនោះផង។ ប្រព័ន្ធបោះឆ្នោតនេះនឹងធានាថាបុគ្គលដែលចង់ឈរឈ្មោះជាតំណាងរាស្ត្រត្រូវតែឃោសនាដោយផ្ទាល់ នៅតាមមូលដ្ឋានដែលខ្លួនចង់ធ្វើជាតំណាងរាស្ត្រដោយមិនចាំបាច់ឱ្យមេបក្សចាត់តាំងខ្លួននោះឡើយ។ ប្រព័ន្ធនេះនឹងជ្រើសរើសបានតំណាងរាស្ត្រដែលឯករាជ្យ និងសេរីភាពគ្រប់គ្រាន់ ដោយគ្មានរងសម្ពាធពីមេបក្សនោះទេ។ តំណាងរាស្ត្រអាចបំពេញការងារជួយកែតម្រង់
រដ្ឋាភិបាលយ៉ាងមានប្រសិទ្ធភាព និងរៀបចំធ្វើច្បាប់ណាដែលបម្រើផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតពិតៗ។

**១២ ស.** *ការបោះឆ្នោតជ្រើសរើស និងការបោះឆ្នោតដកតំណាងគ្រប់លំដាប់ - ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី - ដោយប្រជាពលរដ្ឋផ្ទាល់មានសារៈសំខាន់អ្វីខ្លះ?*

**ច.** នេះគឺជាវិធានការ ដើម្បីធ្វើឱ្យតំណាងប្រជាពលរដ្ឋគ្រប់លំដាប់ - ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងខេត្ត/រាជធានីត្រូវតែទទួលខុសត្រូវផ្ទាល់ ចំពោះមុខប្រជាពលរដ្ឋដែលជាម្ចាស់អំណាច និងដើម្បីកាត់ផ្តាច់ការបញ្ជាតាមខ្សែរយៈបក្សពួកពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន។ តំណាងនៅគ្រប់លំដាប់នឹងយកចិត្តទុកដាក់បំពេញការងារ ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ តាមមូលដ្ឋានជាជាងបម្រើបក្សដែលកំពុងកាន់អំណាច។

**១១ ស.** *អព្យាក្រឹតមន្ត្រីរាជការមានសារៈសំខាន់អ្វីខ្លះ ?*

**ឆ.** នេះគឺជាវិធានការ ដើម្បីធានាឱ្យមានការចាត់តាំងបែងចែកការងាររបស់មន្ត្រីរាជការបានចំជំនាញស្របតាមសមត្ថភាព និងបទពិសោធន៍ការងារ និងផ្តល់សេចក្តីថ្លៃថ្នូរដល់មន្ត្រីរាជការដែលជាភ្នាក់ងាររបស់រដ្ឋ។ ការនៅជាអព្យាក្រឹតនឹងជួយឱ្យមន្ត្រីរាជការបំពេញការងាររបស់ខ្លួនដោយឯករាជ្យ និងមិនរងការគាបសង្កត់ពីគណបក្សដែលកំពុងកាន់អំណាច។ មន្ត្រីរាជការក៏មិនចាំបាច់ខ្វល់ខ្វាយអំពីការបាត់បង់មុខតំណែង ក្រោយពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់អាណត្តិថ្មីម្តងៗ។

**១០ ស.** *ការផ្តល់សេចក្តីសម្រេចទុកចិត្តដោយសភា ដើម្បីជ្រើសតាំងឋានន្តរសក្តិចាប់ពីឧត្តមសេនីយ៍យោធា និងនគរបាលមានសារៈសំខាន់អ្វីខ្លះ ?*

**ឆ.** នេះគឺជាវិធានការដើម្បីធ្វើឱ្យសភាមានឥទ្ធិពលទៅលើនាយទាហាន និងនាយនគរបាលជាន់ខ្ពស់ ដែលជាអ្នកបញ្ជាលើកងកម្លាំងប្រដាប់អាវុធ និងដើម្បីធានាថា កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទនឹងបំពេញតួនាទីរបស់ខ្លួនដោយឯករាជ្យ ដើម្បីរក្សាបូរណភាពទឹកដី សន្តិសុខ និងស្ថិរភាពសង្គម និងដើម្បីទប់ស្កាត់កុំឱ្យមានការប្រើប្រាស់ កងកម្លាំងប្រដាប់អាវុធជាឧបករណ៍ផ្តាច់ការរបស់គណបក្ស ដែលកំពុងកាន់អំណាច។

**៩ ស.** *ការបង្កើតតុលាការរដ្ឋបាលមានសារៈសំខាន់អ្វីខ្លះ ?*

**ឆ.** តុលាការរដ្ឋបាលដើរតួនាទីយ៉ាងសំខាន់សម្រាប់ឱ្យប្រជាពលរដ្ឋប្តឹងមន្ត្រីរាជការនូវរាល់ទង្វើរំលោភបំពាននានារបស់មន្ត្រីរាជការក្នុងការបំពេញការងារ ឬដើម្បីឱ្យប្រជាពលរដ្ឋអាចប្តឹងទៅស្ថាប័ននេះឱ្យពិនិត្យភាពមិនប្រក្រតីនៃលិខិតស្នាម ឬសេចក្តីសម្រេចផ្សេងៗដែលចេញដោយអង្គភាពរដ្ឋបាលសាធារណៈគ្រប់លំដាប់។

**៨ ស.** *ការតម្រូវឱ្យនាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានរដ្ឋមានសារៈសំខាន់អ្វីខ្លះ ?*

**ឆ.** នេះគឺជាវិធានការចាំបាច់ ដើម្បីការការពារសន្តិសុខ និងទំនុកបម្រុងជីវភាពរស់នៅរបស់នាយករដ្ឋមន្ត្រី និងក្រុមគ្រួសាររបស់នាយករដ្ឋមន្ត្រីឱ្យប្រកបដោយសុខុមាលភាព និងសេចក្តីថ្លៃថ្នូរ និងដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបំពេញការងារដោយមានការទទួលខុសត្រូវបានខ្ពស់បំផុត។ នេះក៏ជាវិធានការ ដើម្បទប់ស្កាត់នាយករដ្ឋមន្ត្រីកុំឱ្យគាត់រៀបចំគេហដ្ឋានរបស់គាត់ឱ្យមានទ្រង់ទ្រាយដូចជាបន្ទាយទាហាន ដើម្បីការពារគាត់ និងក្រុមគ្រួសារគាត់ផងដែរ។

**៧ ស.** *ការមិនអនុញ្ញាតឱ្យនាយករដ្ឋមន្ត្រីបង្កើតក្រុមអង្គរក្សដោយខ្លួនឯងមានសារៈសំខាន់អ្វីខ្លះ ?*

**ឆ.** អង្គរក្សការពារនាយករដ្ឋមន្ត្រីគឺជាការចាំបាច់។ ការមិនអនុញ្ញាតឱ្យនាយករដ្ឋមន្ត្រីបង្កើតក្រុមអង្គរក្សដោយខ្លួនឯងគឺដើម្បីធានាថា ក្រុមអង្គរក្សមិនទទួលរងសម្ពាធពីនាយករដ្ឋមន្ត្រី និងអាចបំពេញការងារដោយឯករាជ្យ និងវិជ្ជាជីវៈខ្ពស់ ទទួលខុសត្រូវទាំងការការពារនាយករដ្ឋមន្ត្រីផង និងសហការចាប់ខ្លួននាយករដ្ឋមន្ត្រីផង ក្នុងកាលៈទេសៈតម្រូវឱ្យធ្វើយ៉ាងដូច្នោះ។

**៦ ស.** *ការកំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិមានសារៈសំខាន់អ្វីខ្លះ ?*

**ឆ.** ការកំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិគឺជាការចាំបាច់ ដើម្បីចៀសវាងកុំឱ្យបុគ្គលណាម្នាក់ដែលជានាយករដ្ឋមន្ត្រីមានឱកាសបង្កើតបណ្តាញខ្សែរយៈគ្រួសារ និងបក្ខពួកក្នុងស្ថាប័នរដ្ឋ ដែលជាប្រព័ន្ធពង្រឹងអំណាចបុគ្គលដែលអាចនាំឱ្យមានការបង្កើតរបបផ្តាច់ការ បក្ខពួក ឬក្រុមគ្រួសារនិយម និងការបំផ្លាញផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។ នេះក៏ជាការរំដោះនាយករដ្ឋមន្ត្រីឲ្យរួចផុតពីការទទួលខុសត្រូវលើបញ្ហាទាំងអស់តែម្នាក់ឯងផង និងជាការផ្តល់ឱកាសឲ្យបេក្ខជនផ្សេងៗទៀតអាចមកអនុវត្តបែបបទតាមទិសដៅផ្សេងពីនាយករដ្ឋមន្ត្រីមុនផង។

**៥ ស.** **យន្តការប្រាំបីចំណុចមានអ្វីខ្លះ ?**

**ឆ.** យន្តការប្រាំបីចំណុចរួមមានៈ

១. កំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិ

២. មិនអនុញ្ញាតឱ្យនាយករដ្ឋមន្ត្រីបង្កើតក្រុមអង្គរក្សដោយខ្លួនឯង

៣. តម្រូវឱ្យនាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានរដ្ឋ

៤. បង្កើតតុលាការរដ្ឋបាល

៥. ឋានន្តរសក្តិចាប់ពីឧត្តមសេនីយ៍យោធា និងនគរបាល ត្រូវសុំសេចក្តីទុកចិត្តពីសភា

៦. អព្យាក្រឹតមន្ត្រីរាជការ

៧. បោះឆ្នោតជ្រើសរើស និងបោះឆ្នោតដកតំណាងគ្រប់លំដាប់- ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី - ដោយប្រជាពលរដ្ឋផ្ទាល់

៨. បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមប្រព័ន្ធចម្រុះ

៤ **ស.** តើ គ.ស.ប ពន្យល់អំពីប្រជាធិបតេយ្យ/នយោបាយ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គមដូចម្តេច?

**ច.** គ.ស.ប ពន្យល់អំពីប្រជាធិបតេយ្យ/នយោបាយ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គមដូចខាងក្រោម៖

- ពន្យល់ប្រជាពលរដ្ឋអំពី (១)ប្រជាធិបតេយ្យ (២)ដំណើរការប្រជាធិបតេយ្យ (៣)ធាតុផ្សំប្រជាធិបតេយ្យ និង(៤)ផលប្រជាធិបតេយ្យ
- ពន្យល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពី (១)គោលដៅ (២)ចំណុចចាប់ផ្តើម (៣)ឥរិយាបថនយោបាយ និង(៤)ធនធានមនុស្សនៃការធ្វើនយោបាយរបស់ គ.ស.បដើម្បីបង្កើតសង្គមប្រជាធិបតេយ្យ
- ពន្យល់ប្រជាពលរដ្ឋឱ្យចូលរួមជាមួយ គ.ស.ប ដោយការយល់ដឹងដើម្បីបញ្ចប់ការធ្វើនយោបាយ (១)ដោយការដើរតាម (២)ដោយការស្រលាញ់ និង (៣) ដោយការដឹងគុណមកជាការធ្វើនយោបាយដោយការរួមគិត រួមធ្វើ រួមទទួលខុសត្រូវ
- ពន្យល់ប្រជាពលរដ្ឋឱ្យចូលរួមជាមួយ គ.ស.ប ដើម្បីបញ្ចប់ការចាត់ទុកព្រះធម៌ជាជំនឿសាសនា មកជាការបដិបត្តិព្រះធម៌ដោយការពិចារណារកហេតុផល ដើម្បីធ្វើឱ្យជីវិតរស់នៅមានបុព្វហេតុច្បាស់លាស់នៅក្នុងបច្ចុប្បន្នជាតិ
- ពន្យល់ប្រជាពលរដ្ឋដោយប្រើប្រាស់មេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធអំពីជីវិត ដើម្បីផ្លាស់ប្តូរផ្នត់គំនិតពីភាពអសកម្ម និងអសីលធម៌ឱ្យទៅជាពលរដ្ឋមានសីលធម៌ និងសកម្មក្នុងសកម្មភាពសង្គម
- ពន្យល់ប្រជាពលរដ្ឋឱ្យមានមូលដ្ឋានគ្រឹះសម្រាប់ការអប់រំសីលធម៌ផ្ទាល់ខ្លួន និងការពង្រឹងចំណេះដឹងទូទៅដែលជាមូលដ្ឋាននៃការបញ្ចប់សង្គមដែលពោរពេញទៅដោយការបែងចែកវណ្ណៈទៅជាសង្គមដែលប្រជាពលរដ្ឋទាំងអស់រស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់

៣ **ស.** តើ គ.ស.ប នឹងសម្រេចគោលដៅរបស់ខ្លួនដោយរបៀបណា?

**ច. ដើម្បីឈានទៅសម្រេចគោលដៅ "មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់" គសប ត្រូវផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋលើគោលធំៗចំនួនបី គឺ ៖ ប្រជាធិបតេយ្យ/នយោបាយ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គមនៅដំណាក់កាលដំបូង និងឈានទៅប្រែក្លាយយន្តការ ៨ ចំណុចឲ្យទៅជាច្បាប់នៅតំណាក់កាលបន្ទាប់។**

២ **ស.** អ្វីទៅជាវត្ថុបំណងរបស់ គ.ស.ប?

**ច. តុល្យភាពអំណាចរវាងអ្នកកាន់ការងារស្រុកទេស និងប្រជាពលរដ្ឋ (កាត់បន្ថយអំណាចរដ្ឋ = ប្រជាពលរដ្ឋមានអំណាច)**

១ **ស.** អ្វីទៅជាគោលដៅរបស់ គ.ស.ប?

**ច. មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់។**